# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. 974 MOC / SM 2010

# ប្រកាស
## ស្តីពីការធ្វើប្រតិភូកម្មការងារពាណិជ្ជកម្ម ជូនដល់ ក្រុង ស្រុក ខណ្ឌគោលដៅ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាស លេខ ៩២៧ប្រក ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យប្រជាពលរដ្ឋ នៅក្រុង ស្រុក ខណ្ឌគោលដៅ
- បានឃើញប្រកាស លេខ ៩២៨ ប្រក ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយ នៅក្រុង ស្រុក ខណ្ឌគោលដៅ
- បានឃើញប្រកាស លេខ ០១ សកណ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីរបៀបរបបធ្វើការងាររបស់ក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងសម្រាប់ជួយគាំទ្រដល់ការអនុវត្តគម្រោងសាកល្បង ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌ
- យោងការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## <u>សម្រេច</u>

**<u>ប្រការ ១.</u>-** ត្រូវបានធ្វើប្រតិភូកម្មការងារគ្រប់គ្រងអាជីវកម្ម សេវាកម្មពាណិជ្ជកម្ម ជូនដល់ក្រុង ស្រុក ខណ្ឌគោលដៅដែលមានការិយាល័យច្រកចេញចូលតែមួយ ដើម្បីអនុវត្តនូវវិធាន និងបទបញ្ញត្តិក្នុងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្មជូនដល់អាជីវករជារូបវន្តបុគ្គលដែលមិនជាប់ពន្ធលើប្រាក់ចំណេញ។

2010-11-10 One Stop Service PRAKAS of Delegated(2)(F) KSHTC

ក្រសួងពាណិជ្ជកម្ម
មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥)-២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥)-២៣ ៨៦៦ ១៨៨/៨៦៦ ៨២៥
អ៊ីម៉ែល :moccab@moc.gov.kh

**ប្រការ ២.-** មន្ត្រីជំនាញដែលទទួលបន្ទុកការងារគ្រប់គ្រងអាជីវកម្ម សេវាកម្ម ប្រចាំការនៅការិយាល័យច្រកចេញចូលតែមួយ នៃក្រុង ស្រុក ខណ្ឌគោលដៅ ត្រូវរៀបចំគំរូលិខិតស្នាម ឯកសារបច្ចេកទេស និងអនុវត្តឱ្យបានត្រឹមត្រូវតាមបែបបទ នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ដែលនឹងមានចែងក្នុងសេចក្តីណែនាំដោយឡែក សំដៅលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃសេវារដ្ឋបាលសាធារណៈ ក្នុងវិស័យនេះ ។

**ប្រការ ៣.-** សាលាក្រុង ស្រុក ខណ្ឌគោលដៅ ត្រូវធ្វើរបាយការណ៍ ស្តីពីលទ្ធផលនៃការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ដោយភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ផ្ញើជូនមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដើម្បីជ្រាបជាព័ត៌មាន ។

**ប្រការ ៤.-** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៥.-** នាយិកាខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្តដែលមានក្រុង ស្រុក ខណ្ឌគោលដៅ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- សាលារាជធានី ខេត្តដែលមានក្រុង ស្រុក ខណ្ឌគោលដៅ
- មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
- សាលាក្រុង ស្រុក ខណ្ឌគោលដៅ
- ដូចប្រការ ៥
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ៥៣៩៩ MOC / SM 2010

## សេចក្តីណែនាំ
## ស្តីពីការអនុវត្តន៍ខ្លឹមសារប្រកាសលេខ ១៦៥ MOC / SM 2010 ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការធ្វើប្រតិភូកម្មការងារពាណិជ្ជកម្មជូនដល់ក្រុង ស្រុក ខណ្ឌគោលដៅ

ការធ្វើប្រតិភូកម្មការងារពាណិជ្ជកម្ម គឺជាការអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការផ្តល់សេវាសាធារណៈ ក្នុងគោលបំណងបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរ និងកាន់តែខិតទៅជិតប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ចំណុះក្រុង ស្រុក ខណ្ឌ ធានាបាននូវភាពងាយស្រួលឆាប់រហ័ស និងចំណាយតិចសម្រាប់អាជីវករ។ ការផ្តល់លិខិតអនុញ្ញាតប្រកបអាជីកម្ម សេវាកម្ម គឺជាការទទួលស្គាល់បឋមនូវភាពស្របច្បាប់ជារូបវន្តបុគ្គល ក្នុងការប្រកបអាជីវកម្ម សេវាកម្ម ស្របទៅតាមគោលការណ៍ច្បាប់ជាធរមាន។

ដើម្បីឱ្យការអនុវត្តប្រកាសលេខ ១៦៥ MOC / SM 2010 ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការធ្វើប្រតិភូកម្មការងារពាណិជ្ជកម្ម ជូនដល់ស្រុក ក្រុង ខណ្ឌគោលដៅឱ្យទទួលបានលទ្ធផលល្អ ក្រសួងពាណិជ្ជកម្មសូមធ្វើការណែនាំអនុវត្តអំពីវិធាន បែបបទ និងនីតិវិធីនៃការចេញលិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្ម សេវាកម្ម សម្រាប់អនុវត្តនៅការិយាល័យច្រកចេញចូលតែមួយ នៃក្រុង ស្រុក ខណ្ឌគោលដៅ ដូចខាងក្រោម :

### I – <u>ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្ម</u>

ក- រាល់អាជីវករ ដែលត្រូវមកស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវកម្ម ពីក្រុង ស្រុក ខណ្ឌគោលដៅ ត្រូវមានលក្ខណៈ ដូចខាងក្រោម :

- អាជីវករដែលមានបំណងធ្វើ ឬកំពុងធ្វើសកម្មភាពទិញលក់ ឬធ្វើសេវាជាប្រចាំ ក្នុងគោលដៅធ្វើការដោះដូរ និងស្វែងរកប្រាក់ចំណេញ ហើយមិនជាប់ពន្ធលើប្រាក់ចំណេញ។
- អាជីវករដែលជាប់កាតព្វកិច្ចបង់ប៉ាតង់ជូនរដ្ឋជារៀងរាល់ឆ្នាំក្នុងដំណើរការអាជីវកម្ម សេវាកម្មរបស់ខ្លួន។
- អាជីវករណាដែលមានទីតាំងប្រកបមុខរបររបស់ខ្លួន ជាអចិន្ត្រៃយ៍។

ខ - ក្រោយពីចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្មរួចហើយនោះ អាជីវករទាំងអស់ ត្រូវគោរពទៅតាមបទបញ្ញត្តិផ្សេងៗពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម សេវាកម្ម ដែលរដ្ឋបានកំណត់។

- ក្នុងករណីមានការផ្លាស់ប្តូរទីតាំងប្រកបអាជីវកម្ម សេវាកម្ម ឬនាមករណ៍(ស្លាកយីហោ) ឬមួយផ្លាស់ប្តូរអ្នកគ្រប់គ្រង អាជីវករត្រូវផ្តល់ព័ត៌មានមកការិយាល័យច្រកចេញចូលតែមួយ ដើម្បីធ្វើការកែសម្រួល ។



ក្រសួងពាណិជ្ជកម្ម
មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ : (៨៥៥)-២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥)-២៣ ៨៦៦ ១៨៨/៨៦៦ ៨២៥
អ៊ីម៉ែល :moccab@moc.gov.kh

គ - អ្នកស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្ម ត្រូវបង់ប្រាក់ចំនួន ២៥.០០០រៀល សម្រាប់កម្រៃរដ្ឋបាល ដែលរួមមាន :

+ពាក្យស្នើសុំចំនួន ៥.០០០រៀល

\+ បិទតែមប្រើចំនួន ១.០០០រៀល

+បង្កាន់ដៃទទួលពាក្យចំនួន ១.០០០រៀល

+គុណប្រយោជន៍រដ្ឋបាលឃុំចំនួន ៣.០០០រៀល

+សោហ៊ុយសេវារដ្ឋបាលចំនួន ១៥.០០០រៀល

កំរៃរដ្ឋបាលខាងលើនេះ នឹងត្រូវបានកែប្រែតាមការកំណត់របស់ប្រកាសអន្តរក្រសួង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

## II – ទម្រង់បែបបទនៃការស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវកម្ម

សំណុំបែបបទដែលត្រូវបំពេញ ( មានគំរូជូនភ្ជាប់មកជាមួយ) រួមមាន :

-ពាក្យស្នើសុំប្រកបអាជីវកម្ម សេវាកម្ម ( មានបិទតែមប្រើ) ចំនួន ០១ ច្បាប់

-អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ( បើជាជនបរទេស) ថតចម្លង ចំនួន ០១ ច្បាប់

-ជីវប្រវត្តិសង្ខេប ចំនួន ០១ ច្បាប់

-រូបថតចំពីមុខ ( ទំហំ ៤ x ៦ ) ចំនួន ០២ សន្លឹក

-ប័ណ្ណប៉ាតង់ ថតចម្លង ( បើមាន) ចំនួន ០១ ច្បាប់

-កិច្ចសន្យា ចំនួន ០១ ច្បាប់

## III – នីតិវិធីនៃការអនុវត្តន៍

-មន្ត្រីទទួលពាក្យស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយ ត្រូវពិនិត្យលើទម្រង់បែបបទ ដែលអាជីវករបានមកដាក់ពាក្យស្នើសុំ ដើម្បីធានាភាពត្រឹមត្រូវគ្រប់គ្រាន់តាមសេចក្តីណែនាំ។ ក្នុងករណីដែលពិនិត្យឃើញថា ពាក្យស្នើសុំរបស់អាជីវករពុំទាន់បានបំពេញ ឬមិនចេះបំពេញតាមបែបបទកំណត់នោះ មន្ត្រីប្រចាំការត្រូវពន្យល់ណែនាំ និងជួយដល់អាជីវករ ក្នុងការបំពេញបន្ថែមលើពាក្យស្នើសុំនោះឱ្យបានគ្រប់គ្រាន់តាមលក្ខខ័ណ្ឌតម្រូវ ។

-ក្នុងករណីដែលបែបបទនៃការដាក់ពាក្យស្នើសុំ គ្រប់គ្រាន់ត្រឹមត្រូវតាមសេចក្តីណែនាំហើយនោះ មន្ត្រីទទួល-ប្រគល់ពាក្យស្នើសុំ ត្រូវចុះលេខចូល ដោយបញ្ជាក់ថ្ងៃ ខែ ឆ្នាំ និងម៉ោង នៃការទទួលពាក្យ រួចចេញបង្កាន់ដៃទទួលពាក្យឱ្យអ្នកស្នើសុំ ហើយបញ្ជូនទៅមន្ត្រីមានសមត្ថកិច្ចរបស់ការិយាល័យពាណិជ្ជកម្ម ដែលប្រចាំការនៅការិយាល័យច្រកចេញចូលតែមួយ ។

-ការិយាល័យពាណិជ្ជកម្មប្រចាំក្រុង ស្រុក ខណ្ឌគោលដៅត្រូវប្រថាប់ត្រាចូលលើពាក្យស្នើសុំ ដោយមានបញ្ជាក់ថ្ងៃ ខែ ឆ្នាំ និងម៉ោងចូល ហើយត្រូវពិនិត្យសំណុំឯកសារពាក្យសុំ និងចុះអង្កេតពិនិត្យព្រមទាំងវាយតម្លៃផ្តល់យោបល់ជូនអភិបាល ក្រុង ស្រុក ខណ្ឌដើម្បីពិនិត្យ និងសម្រេច មិនឱ្យហួសពីដប់ម៉ោង ( ១០ ម៉ោង) នៃថ្ងៃធ្វើការ ។



ក្រសួងពាណិជ្ជកម្ម
មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) -២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥) -២៣ ៨៦៦ ១៨៨/៨៦៦ ៨២៥
អ៊ីម៉ែល :moccab@moc.gov.kh

-សន្លឹកប័ណ្ណ " **លិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម** " ត្រូវបានផ្តល់ជូនដោយក្រសួងពាណិជ្ជកម្ម ដើម្បីឱ្យការិយាល័យច្រកចេញចូលតែមួយប្រើប្រាស់តាមគំរូឯកភាព។

-លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេលមួយឆ្នាំ។ មុនផុតកំណត់រយៈពេល ១៥ ថ្ងៃ យ៉ាងយូរ អាជីវករត្រូវដាក់ពាក្យសុំបន្តប្រកបអាជីវកម្ម សេវាកម្ម។

-រាល់អាជីវករ ដែលមិនបានបំពេញកាតព្វកិច្ចដូចមានចែងខាងលើនោះ នឹងត្រូវចាត់ទុកថាជាការប្រកបអាជីវកម្ម សេវាកម្មមិនស្របច្បាប់ ព្រមទាំងអាចត្រូវទទួលការអប់រំ និងពិន័យ ដូចខាងក្រោម :

- លើកទី ១ : ធ្វើការណែនាំឱ្យអនុវត្ត
- លើកទី ២ : ធ្វើលិខិតព្រមានដើម្បីឱ្យមកបំពេញបែបបទតាមច្បាប់ជាធរមាន
- លើកទី ៣ : ក្នុងករណីនៅតែមិនអនុវត្ត សាលាក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតគណៈកម្មការអប់រំ ពិន័យ ឬផ្អាកសកម្មភាពអាជីវកម្មជាបណ្តោះអាសន្ន ដើម្បីតម្រូវឱ្យអនុវត្ត។

ទទួលបានសេចក្តីណែនាំនេះ មន្ត្រីមានសមត្ថកិច្ចប្រចាំការិយាល័យច្រកចេញចូលតែមួយ នៃក្រុង ស្រុក ខណ្ឌគោលដៅ និងប្រជាពលរដ្ឋ អាជីវករ ដែលធ្វើសកម្មភាពអាជីវកម្ម សេវាកម្ម ក្នុងក្រុង ស្រុក ខណ្ឌគោលដៅ ត្រូវអនុវត្តទៅតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- សាលារាជធានី ខេត្តដែលមានក្រុង ស្រុក ខណ្ឌគោលដៅ
- មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត
- សាលាក្រុង ស្រុក ខណ្ឌគោលដៅ
- ឯកសារ- កាលប្បវត្តិ



ក្រសួងពាណិជ្ជកម្ម
មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥)-២៣ ៨៦៦ ០៨៨/៨៦៦ ៨៧៨
ទូរសារលេខ: (៨៥៥)-២៣ ៨៦៦ ១៨៨/៨៦៦ ៨២៥
អ៊ីម៉ែល :moccab@moc.gov.kh